**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

លេខ ......១៥៨...... រ.ស.

# សេចក្តីសម្រេច

## ប្រធានរដ្ឋសភា

- **បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**
- **បានឃើញសេចក្តីសម្រេចលេខ ១៥០/004/២០១៤ កបធ.ច ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ របស់ក្រុមប្រឹក្សាធម្មនុញ្ញស្តីពីការពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា**

## សម្រេច

**ប្រការ ១.**

ប្រកាសឲ្យប្រើវិសោធនកម្មប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី ៥ អនុម័តនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ។

**ប្រការ ២.**

សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : ( ៨៥៥-២៣ ) ២១៣ ៥៣៥, ២២០ ៦២៨, ទូរសារ : ( ៨៥៥-២៣ ) ២២០ ៦២៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

# វិសោធនកម្ម
# ប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា
# នៃព្រះរាជាណាចក្រកម្ពុជា

**ប្រការតែមួយ** :

ប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកែប្រែដូចតទៅ :

**ប្រការ ៦ ថ្មី** ( **ពីរ** ) :

គណៈកម្មការនានា នៃរដ្ឋសភាមាន :

**១**-គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា

**២**-គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

**៣**-គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

**៤**-គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ

**៥**-គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

**៦**-គណៈកម្មការនីតិកម្ម និងយុត្តិធម៌

**៧**-គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍

**៨**-គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកិច្ចការនារី

៩-គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

១០-គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ ។

វិសោធនកម្មនេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**